# លោក ហ៊ុន សែន រងការរិះគន់ករណីលុបស.ជ.ណ ចាប់ខ្លួនឧកញ៉ា សៀង ចាន់ហេង។



(ពីឆ្វេងជូរមុខ) អ្នកស្រី ប៊ុន រ៉ានី លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងឧកញ៉ា សៀង ចាន់ហេង នាយិកាក្រុមហ៊ុនហេងអភិវឌ្ឍន៍ ក្នុងកម្មវិធីកាកបាទក្រហមកម្ពុជា កាលពីឆ្នាំ២០១៨។

មន្ត្រីអង្គការសង្គមស៊ីវិល និងតំណាងសហគមន៍ដីធ្លីរិះគន់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលលុបស.ជ.ណ ចាប់ខ្លួនឧកញ៉ា សៀង ចាន់ហេង នាយិកាក្រុមហ៊ុនហេងអភិវឌ្ឍន៍។ ពួកគេថា អាជ្ញាធរអាចចាប់ខ្លួនតែពលរដ្ឋក្រីក្រដែលតវ៉ាការពារទំនាស់ដីធ្លីរបស់ខ្លួន។ ប្រតិកម្មនេះធ្វើឡើង បន្ទាប់ពី លោក ហ៊ុន សែន

ប្រកាសលុបស.ជ.ណចាប់ខ្លួននាយិកាក្រុមហ៊ុនហេងអភិវឌ្ឍន៍ គឺអ្នកស្រី សៀង ចាន់ហេង កាលពីថ្ងៃទី១១ មករា ដែលបានបន្លំឯកសារកាន់កាប់ដីធ្លីរបស់អ្នកដទៃ។

មន្ត្រីសង្គមស៊ីវិល និងតំណាងសហគមន៍ដីធ្លីលើកឡើងថា ការដែលលោក ហ៊ុន សែន លុបស.ជ.ណចាប់ខ្លួនមនុស្សខិលខូចបែបនេះ នឹងធ្វើឱ្យប្រជាពលរដ្ឋអ្នកមានទំនាស់ដីធ្លី កាន់តែរងភាពអយុត្តិធម៌ និងមានការឈឺចាប់កាន់តែខ្លាំង។

អ្នកសម្របសម្រួលគម្រោងធុរកិច្ច និងសិទ្ធិមនុស្សនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លោក វណ្ណ សុផាត ប្រាប់វិទ្យុអាស៊ីសេរី នៅថ្ងៃទី១២ មករា ថា ការដែលលោក ហ៊ុន សែន លុបស.ជ.ណ ចាប់ខ្លួនឧកញ៉ា សៀង ចាន់ហេង ដែលបានធ្វើឯកសារក្លែងបន្លំដីធ្លីរបស់អ្នកដទៃគឺជាការអនុវត្តច្បាប់ស្តង់ដារពីរ ដែលខុសពីប្រជាពលរដ្ឋក្រីក្រដោយគ្រាន់តែពួកគាត់តវ៉ាបញ្ហាទំនាស់ដីធ្លី ហើយត្រូវបានអាជ្ញាធរចាប់ខ្លួនពួកគេដាក់ពន្ធនាគារជាច្រើនករណី ដោយពុំមានការជួយអន្តរាគមន៍ពីលោកនាយករដ្ឋមន្ត្រីឡើយ។ លោកបញ្ជាក់ថា ការធ្វើបែបនេះនឹងធ្វើឱ្យប្រជាពលរដ្ឋអស់ជំនឿលើរដ្ឋាភិបាល ហើយធ្វើឱ្យជីវភាពពួកគាត់កាន់តែក្រីក្រ ព្រោះបាត់បង់ដីធ្លីដោយសារតែអ្នកមានលុយនិងមានអំណាចរំលោភយក។

លោក វណ្ណ សុផាត៖ *«ប្រទេសណាដែលមិនសូវមានការគោរពច្បាប់ ហើយតែងតែរំលោភដីធ្លីរបស់ប្រជាពលរដ្ឋអ៊ីចឹង យើងឃើញប្រទេសហ្នឹងភាគច្រើនអត់បានចម្រុងចម្រើនទេ។ ដូចឃើញប្រទេសស្រីលង្កា មានការធ្លាក់ចុះ ហើយរហូតដល់មានកាប់ដីកាប់អីចឹងទៅឱ្យប្រទេសផ្តល់កម្ចីអ៊ីចឹង។ បើយើងប្រៀបធៀបទៅប្រទេសដែលគេគោរពសិទ្ធិមនុស្ស ប្រជាពលរដ្ឋរបស់គេ ដូចជានៅសាំងហ្គាពួរ អីចឹងគេប្រជាពលរដ្ឋតិចជាងយើងទេ ប៉ុន្តែប្រទេសគេអភិវឌ្ឍន៍ជឿនលឿនដោយសារតែគេគិតគូរពីរឿងជីវភាពរបស់ប្រជាពលរដ្ឋ»។*

ប្រតិកម្មរបស់មន្ត្រីសង្គមស៊ីវិលនេះ ធ្វើឡើងបន្ទាប់ពីលោក ហ៊ុន សែន កាលថ្ងៃទី ១១ ខែមករា បានបង្ហោះតាមបណ្ដាញសង្គមហ្វេសប៊ុករបស់លោកលុបស.ជ.ណា ចាប់ខ្លួននាយិកាក្រុមហ៊ុនហេងអភិវឌ្ឍន៍ គឺអ្នកស្រី សៀង ចាន់ហេង វិញ តាមសំណើរបស់អ្នកស្រី។ លោក ហ៊ុន សែន អះអាងថា លោក និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង ជាអ្នកចេញ ស.ជ.ណា បញ្ជាចាប់ខ្លួនអ្នកស្រី សៀង ចាន់ហេង កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ ពាក់ព័ន្ធនឹងករណីក្លែងបន្លំឯកសារដើម្បីកាន់កាប់អចលនវត្ថុរបស់ឈ្មោះ ហៀវ លន់ នៅភូមិទួលសាលា ឃុំស្អាងភ្នំ ស្រុកស្អាង ខេត្តកណ្ដាល និងលោកស្រី ហ៊ុន ប៊ុនធឿន ដែលជាប្អូនរបស់លោក ហ៊ុន សែន មានតួនាទីជាទីប្រឹក្សាក្រសួងការបរទេស និងជាទីប្រឹក្សាគណៈសង្ឃនាយក គណៈមហានិកាយ។

អ្នកស្រី សៀង ចាន់ហេង គឺជានាយិកាក្រុមហ៊ុន ហេង អភិវឌ្ឍន៍ និងតែងតែដើរ ជាមួយសាច់ញាតិរបស់លោក លោក ហ៊ុន សែន។ ក្រុមហ៊ុន ហេង អភិវឌ្ឍន៍ មានដីរាប់រយហិកតារនៅតាមបណ្ដាខេត្តក្រុងជាច្រើននៅក្នុងប្រទេសកម្ពុជា និងធ្លាប់មានរឿងអាស្រូវជាយូរមកហើយ រឿងប្រើឥទ្ធិពលឃុបឃិតជាមួយអាជ្ញាធរច្បាមយកដីរបស់ពលរដ្ឋក្រីក្រជាច្រើនកន្លែង។ ជាឧទាហរណ៍ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៦ តុលាការក្រុងភ្នំពេញ បានផ្ដន្ទាទោសអ្នកស្រី សៀង ចាន់ហេង ឬដែលគេតែងហៅថា ជំទាវហេងនោះ ឲ្យជាប់ពន្ធនាគាររយៈពេល ១ឆ្នាំ មានទោសពីបទក្លែងបន្លំឯកសារដីជិត ២០០ហិកតារ នៅខេត្តកំពង់ឆ្នាំង ហើយប្រើប្រាស់ឯកសារដីក្លែងនោះលក់ដីទៅឲ្យអ្នកផ្សេងទៀត ។ ប៉ុន្តែអ្នកស្រីមិនត្រូវបានអាជ្ញាធរចាប់ឃុំខ្លួនឡើយ។

វិទ្យុអាស៊ីសេរីពុំអាចសុំការឆ្លើយតបពីអ្នកស្រី សៀង ចាន់ហេង បានទេ នៅថ្ងៃទី ១២ មករា ដោយអ្នកលើកទូរស័ព្ទ ប្រាប់ថា ច្រឡំលេខ។

ជុំវិញរឿងនេះតំណាងសហគមន៍ដីធ្លីនៅខេត្តកោះកុង លោកស្រី ផាវ ញ៉ឿង ថ្លែងថា លោកស្រីមិនពេញចិត្តនឹងវិធានការរបស់លោក ហ៊ុន សែន ដែលជួយអន្តរាគមន៍ដល់ជនខិលខូចនោះទេ ។ លោកស្រីថា រឿងរាវទំនាស់ដីធ្លីរបស់លោកស្រីប្រមាណ ២០ឆ្នាំមកហើយ តែលោក ហ៊ុន សែន ដែលមិនអើពើជួយអន្តរាគមន៍ដល់សហគមន៍ពួកលោកស្រីឡើយ។ លោកស្រីចាត់ទុកការលុបស.ជ.ណ ដែលបញ្ជាឱ្យចាប់ខ្លួនអ្នកមានទ្រព្យធនដែលស្និទ្ធនឹងគ្រួសារលោក ហ៊ុន សែន នេះថា ជាការធ្វើបាបផ្លូវចិត្តដល់ពលរដ្ឋទំនាស់ដីធ្លីក្រីក្រឱ្យកាន់តែឈឺចាប់ថែមទៀត។

លោកស្រី ផាវ ញ៉ឿង៖ *«ព្រោះអីខ្ញុំជាជនរងគ្រោះ ហើយរាល់ថ្ងៃនេះខ្ញុំស្ថិតនៅក្នុងបញ្ជីខ្មៅ ដែលតុលាការចោទប្រកាន់ពីបទញុះញង់បង្កភាពវឹកវរឱ្យអសន្តិសុខសង្គម។ ខ្ញុំចង់ផ្ញើសារទៅលោក ហ៊ុន សែន វិញថា ខ្ញុំគឺជាជនរងគ្រោះដែលបានកាន់កាប់អាស្រ័យផលលើដីឯកជនរបស់រដ្ឋ មុនច្បាប់ភូមិបាលអនុម័តប្រកាស នៅថ្ងៃទី៣០ខែសីហា ឆ្នាំ២០០១ ហើយ ត្រូវចោរប្លន់មកយកដីរបស់ខ្ញុំ ហើយខ្ញុំទៅតវ៉ាមិនមែនជាជនបង្កឱ្យអសន្តិសុខ សង្គមទេ។ អ៊ីចឹងសុំលោក ហ៊ុន សែន ជួយអន្តរាគមន៍មកពួកខ្ញុំនៅខេត្តកោះកុងផង ដើម្បីដោះស្រាយបញ្ហានេះ។ ក្នុងខេត្តកោះកុងមានជាប់បណ្ដឹងជាង ៣០ឯណោះ អ្នកដែលរងគ្រោះដីធ្លី ហេតុអីបានជាលោក ហ៊ុន សែន មិនជួយអន្តរាគមន៍មិនដោះស្រាយឱ្យពួកខ្ញុំ បែរជាអន្តរាគមន៍អត់ឱ្យចាប់ខ្លួនចោរទៅវិញ»*។

ទាក់ទងនឹងបញ្ហានេះប្រធានអង្គការភាពអ្នកនាំពាក្យរដ្ឋាភិបាលលោក ផៃ ស៊ីផាន ប្រាប់វិទ្យុអាស៊ីសេរីយ៉ាងខ្លីថា លោកពុំបានដឹងពីខ្លឹមនៃស.ជ.ណ បញ្ជាចាប់ខ្លួននឹងដោះលែងនេះទេ។

ទោះជាយ៉ាងណានេះ មិនមែនជារឿងថ្មីទេ ដែលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន តែងចេញមុខអន្តរាគមន៍ជួយមនុស្សនៅក្បែរ ឬអ្នកធ្វើការងារបម្រើផល

ប្រយោជន៍ក្រុមគ្រួសាររបស់លោកនោះ។ ថ្មីៗនេះ លោក បានចេញមុខធានាឱ្យអាជ្ញាធរដោះលែងអ្នកអត្ថាធិប្បាយព័ត៌មានអន្តរជាតិនៅទូរទស្សន៍បាយ័នរបស់កូនស្រីលោក គឺអ្នកស្រី ហ៊ុន ម៉ាណា ដែលត្រូវបានតុលាការឃុំខ្លួន ពាក់ព័ន្ធនឹងការចោទប្រកាន់រឿងលក់ដីខ្យល់ តម្លៃប្រមាណ ៣៦លានដុល្លារ។ ករណីនេះ លោក ហ៊ុន សែន ខឹងខ្លាំងរហូតដល់ព្រមានដកតួនាទីមន្ត្រីនគរបាលយុត្តិធម៌ទៀតផង។

រហូតមកទល់ពេលនេះ ករណីឃុបឃិតគ្នារវាងអ្នកមានអំណាច អ្នកមានទ្រព្យធនជាមួយអាជ្ញាធរមូលដ្ឋានធ្វើឯកសារ ឬបន្លំឯកសារយកដីពលរដ្ឋ កំពុងកើតមានជាច្រើនករណីធ្វើឲ្យពលរដ្ឋខ្មែរជាច្រើនគ្រួសារ ចេញតវ៉ា ប៉ុន្តែអាជ្ញាធរ និងតុលាការពុំស្វែរកយុត្តិធម៌ជូនពួកគេឡើយ បើទោះជាពេលខ្លះពួកគាត់បានលើកគ្នាម្តងជាពីរដង ទៅរាជធានីភ្នំពេញ ដើម្បីសុំអន្តរាគមន៍ពីស្ថាប័នពាក់ព័ន្ធ ឬពីលោក ហ៊ុន សែន ក្តី។ ធ្ងន់ធ្ងរជាងនេះ មានករណីមួយចំនួន  ដែលពលរដ្ឋម្ចាស់ដី បែរជាត្រូវបានអាជ្ញាធរចាប់ឃុំខ្លួនទៅវិញ ដោយសារការតវ៉ាការពារដីធ្លីរបស់ពួកគាត់៕